# មេរៀនទី ១៥៥: អេសធើរបានសង្គ្រោះជាតិសាសន៍របស់នាង

## នាងអេសធើរ ២-៩

| | |
|---|---|
| **គោលបំណង៖** | ព្រះមានផែនការសម្រាប់អ្នក។ |

**ខគម្ពីរចងចាំ៖ អេភេសូ ២:១០** *"ដ្បិតយើងរាល់គ្នាជាស្នាដៃ ដែលទ្រង់បង្កើតក្នុងព្រះគ្រីស្ទយេស៊ូវសំរាប់ការល្អ ដែលព្រះបានរៀបចំជាមុន ឲ្យយើងរាល់គ្នាប្រព្រឹត្តតាម។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**

អ្នកដើរតាមព្រះយេស៊ូវ ត្រូវបានដើរតួខុសៗគ្នានៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ សូមអាន **នាងអេសធើរ ៤:១៤** សារឡើងវិញ។ ផ្ដែកទៅលើអត្ថបទនេះ តើនឹងមានរឿងអ្វីកើតឡើងប្រសិនបើយើងបដិសេធមិនដើរតាមផែនការរបស់ព្រះ? តើនឹងមានរឿងអ្វីកើតឡើងចំពោះយើង? ហេតុអ្វីបានជាព្រះបង្ហាញយើងពីតួនាទីជាក់លាក់ និងពេលវេលាជាក់លាក់នោះ? សូមសញ្ជឹងគិតពីបីសំណួរខាងលើនេះ? បន្ទាប់មកសូមអធិស្ឋានបែបនេះ៖ "ឲ្យព្រះយេស៊ូវអើយ សូមទ្រង់បង្ហាញខ្ញុំឲ្យចូលរួមក្នុងពន្ធកិច្ចរបស់ព្រះអង្គដែលមានសម្រាប់ខ្ញុំ ហើយយើងខ្ញុំសូមអរព្រះគុណព្រះអង្គដែលតែងតែជួយឲ្យរឿងគ្រប់យ៉ាង បានទទួលនូវលទ្ធផលល្អនូវរាល់គ្រប់កិច្ច-ការ ដែលទ្រង់បានដាក់ឲ្យខ្ញុំធ្វើ។"

**ចំរៀង៖** ១. ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ ២. ព្រះអង្គទ្រង់អស្ចារ្យ ៣. ខ្ញុំនឹងទុកចិត្តទ្រង់

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «ខ្លែងឆាបកូនមាន់»



១. ចែកកុមារជា ២ក្រុម ឬច្រើនជាងនេះ។

២. ក្នុងក្រុមនីមួយៗកុមារត្រូវតោងចង្កេះគ្នា។ អ្នកដែលនៅឈរមុខគេគឺត្រូវតាមចាប់យកអ្នកក្រោយគេនៃក្រុមផ្សេងទៀត ហើយក៏ត្រូវព្យាយាមការពារកូនក្រុមខ្លួនឯងផងដែរ (កន្ទុយក្រោយគេ។)

៣. គោលបំណងនៃល្បែងនេះគឺបង្ហាញពីការព្យាយាមការពារគ្នាទៅវិញទៅមក។ ក្រុមដែលតោងគ្នាមិនជាប់ (នឹងចាញ់ល្បែងនេះដោយស្វ័យប្រវត្តិ) ហើយក្រុមដែលមានសមាជិករបស់ខ្លួនត្រូវគេចាប់បានក៏ចាញ់ល្បែងនេះដែរ។

៤.បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងត្រូវតែការពារគ្នាទៅវិញទៅមកពីសត្រូវរបស់យើង ពីព្រោះព្រះតែងតែមានផែនការដ៏អស្ចារ្យសម្រាប់មនុស្សគ្រប់គ្នា។

### ៤. ការណែនាំមេរៀន

តើអ្នកគិតថាអ្នកអាចផ្លាស់ប្តូរពិភពលោកនេះបានដែរឬទេ? តើអ្នកគិតថាអ្នកអាចធ្វើឲ្យមានឥទ្ធិពលដ៏ធំសម្រាប់ពិភពលោកនេះដែរឬទេ? តើអ្នកគិតថាបំណងប្រាថ្នាដ៏ធំបំផុតនៅក្នុងជីវិតរបស់អ្នកគឺជាអ្វី? ហេតុអ្វីបានជាព្រះបង្កើតអ្នកឡើង? ថ្ងៃនេះ យើងនឹងរៀនពីផែនការរបស់ព្រះ ដែលមានចំពោះក្មេងស្រីធម្មតាម្នាក់នៅក្នុងព្រះគម្ពីរ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ជាយូរលង់ណាស់មកហើយនៅក្នុងទីក្រុងពើស៊ី គឺមានស្តេចដ៏កំសត់ម្នាក់ដែលមានព្រះនាមថា អ័ហាស៊ូរុស។ ទ្រង់គឺនៅម្នាក់ឯងដោយសារតែទ្រង់មិនមានអគ្គមហេសីនោះទេ។ ដូច្នេះទ្រង់ក៏បានប្រាប់ឲ្យអ្នកបម្រើរបស់ទ្រង់ចេញទៅស្វែងរកស្ត្រីដែលមានសម្រស់ស្អាតដាច់គេតាមតែអាចធ្វើទៅបាន។ អ្នកបម្រើបានស្វែងរកហើយរកទៀត រហូតបានរកឃើញក្មេងស្រីម្នាក់ដែលមានឈ្មោះថា អេសធើរ។

នាងត្រូវបានគេចាប់យកទៅទីក្រុង ដើម្បីឲ្យដឹងថាស្តេចចង់បាននាងធ្វើជាអគ្គមហេសីឬអត់។ ពីមុនអេសធើរបានចាកចេញពីផ្ទះរបស់របស់នាង និងផ្ទះរបស់ជីដូនមួយរបស់នាង។ ម៉ាដេកាយបានប្រាប់នាងថា មិនត្រូវប្រាប់នរណាម្នាក់ថា នាងជាជនជាតិយូដានោះទេ ដោយព្រោះតែមានមនុស្សជាច្រើនមិនចូលចិត្តសាសន៍យូដាឡើយ។ ស្តេចគឺពេញចិត្តនឹងអេសធើរជាខ្លាំង ហើយទ្រង់បានយកនាងធ្វើជាអគ្គមហេសីរបស់ព្រះអង្គទៀតផង ។

ស្តេចក៏មានអ្នកជនិតរបស់ទ្រង់ផងដែរ គឺជាម្នាក់ដែលមានអំណាចជិតស្មើនឹងព្រះអង្គ។ គាត់មានឈ្មោះថា ហាម៉ាន។ ហាម៉ាន មិនចូលចិត្តសាសន៍យូដានោះទេ។ គាត់ល្ងីល្ងើ និងអាក្រក់ខ្លាំងណាស់។ គាត់បានបញ្ចុះបញ្ចូលឲ្យស្តេចបង្កើតច្បាប់ដ៏អាក្រក់មួយ។ នៅក្នុងច្បាប់នោះបាននិយាយថា នៅថ្ងៃពិសេសជនជាតិយូដាត្រូវតែសម្លាប់ទាំងអស់។

នៅពេលដែល ម៉ាដេកាយបានរៀនពីច្បាប់ថ្មីគាត់ក៏ចាប់យំឡើង និងស្រែកយំខ្លាំងៗ។ គាត់គឺពិតជាមានការសោកសៅខ្លាំងណាស់ ហើយថែមទាំងហែកសំលៀកបំពាក់ខ្លួនទៀតផង។ បន្ទាប់មកគាត់ក៏បានផ្ញើសារទៅកាន់ជីដូនមួយរបស់គាត់គឺម្ចាស់ក្សត្រី។ គាត់បានប្រាប់ទៅម្ចាស់ក្សត្រី អេសធើរឲ្យទៅទូលសុំឲ្យស្តេចប្តូរច្បាប់នោះចេញ ដើម្បីជួយសង្គ្រោះសាសន៍យូដា។ ប៉ុន្តែគឺមិនមាននរណាម្នាក់ត្រូវបានអនុញ្ញាតឲ្យចូលទៅគាល់ស្តេចបាននោះទេ ប្រសិនបើស្តេចមិនបានកោះហៅឲ្យចូលគាល់នោះ។ ម្ចាស់ក្សត្រីអេសធើរមានការភ័យខ្លាចជាខ្លាំង។ ប៉ុន្តែម៉ាដេកាយ បានប្រាប់មិនឲ្យនាងមានការភ័យខ្លាចនោះទេ។ គាត់បាននិយាយថា ព្រះបានអនុញ្ញាតឲ្យនាងក្លាយជាម្ចាស់ក្សត្រី ដូច្នេះនាងត្រូវតែជួយសង្គ្រោះដល់សាសន៍យូដា។ ដូច្នេះ ម្ចាស់ក្សត្រីអេសធើរព្រមទាំងអ្នកបម្រើរបស់នាង និងជនជាតិយូដាទាំងអស់បានអធិស្ឋានតមរយៈពេលបីថ្ងៃ។

បន្ទាប់មកម្ចាស់ក្សត្រីអេសធើរបានដើរទៅកាន់ព្រះរាជវាំងខាងក្នុង។ តើមានអ្វីកើតឡើង? ប្រសិនបើទ្រង់កាន់ដំបងមាស នោះនាងអាចរស់បន្ត។ ប៉ុន្តែប្រសិនបើទ្រង់មិនកាន់ដំបងទេនោះនាងនឹងស្លាប់។ នៅពេលដែលអេសធើរបើកទ្វារចូលទៅ ស្តេចគឺកំពុងតែកាន់ដំបងមាសរបស់ព្រះអង្គ។ ស្តេចបានសន្យាថា ទ្រង់នឹងប្រទានឲ្យគ្រប់យ៉ាងដែលនាងសុំ។ នាងបានអញ្ជើញស្តេច និងហាម៉ានទៅសោយអាហារ។ នៅក្នុងពេលសោយអាហារនាងបានទូលប្រាប់ស្តេចពីផែនការដ៏អាក្រក់ដែលហាម៉ានចង់សម្លាប់ជនជាតិយូដា។ ស្តេចមានការខ្ញាល់ជាខ្លាំង។ ហាម៉ានក៏ត្រូវបានសម្លាប់ ហើយម៉ាដេកាយក៏បានក្លាយជាអ្នកជំនិតរបស់ស្តេចជំនួសវិញ ហើយជនជាតិយូដាទាំងអស់ក៏ត្រូវបានសង្គ្រោះផងដែរ។

ព្រះមានផែនការសម្រាប់ម្ចាស់ក្សត្រីអេសធើរ។ នៅពេលដែលនាងដើរតាមផែនការរបស់ព្រះ ជនជាតិយូដាទាំងអស់ក៏ត្រូវបានសង្គ្រោះ។ ព្រះបានបង្កើតយើងទាំងអស់គ្នាមកតាមផែនការរបស់ព្រះអង្គ ហើយទ្រង់គឺមានការងារសម្រាប់យើងម្នាក់ៗក្នុងការបំពេញផងដែរ។ ព្រះគម្ពីរបានប្រាប់យើងថា យើងបានបង្កើតឡើងដើម្បីធ្វើកិច្ចការល្អ

។ ហើយព្រះបានសន្យាថាទ្រង់នឹងគង់ជាមួយ និងជួយដល់យើងក្នុងការបំពេញកិច្ចការទាំងអស់នោះ។ ពួកយើងគឺបម្រើព្រះដ៏ល្អ និងមានព្រះចេស្តាដែលទ្រង់បានបង្កើតផែនការដ៏អស្ចារ្យសម្រាប់ប្រជារាស្ត្ររបស់ព្រះអង្គ។

**៦. សំនួរពិភាក្សា**

១. តើមូលហេតុអ្វីបានស្តេចអ័ហាស៊ូរុសក្រៀមក្រំ? *ពីព្រោះទ្រង់មិនមានអគ្គមហេសី*

២. តើនរណាដែលក្លាយជាម្ចាស់ក្សត្រីបន្ទាប់របស់ស្តេចអ័ហាស៊ូរុស? *អេសធើរ*

៣. តើផែនការដ៏អាក្រក់របស់ហាម៉ានគឺជាអ្វី? *សម្លាប់ជនជាតិយូដាទាំងអស់*

៤. តើម្ចាស់ក្សត្រីអេសធើរគួរធ្វើអ្វីខ្លះ ដើម្បីសង្គ្រោះសាសន៍យូដា? *នាងគួរតែទៅជួបស្តេចបើទោះបី ជាស្តេចមិនបានអញ្ជើញនាង បើទោះបីជានាងអាចមានទោសដល់ស្លាប់ដ៏ដោយ*

៥. តើព្រះបានប្រើអេសធើរដោយរបៀបណា? *នាងបានសង្គ្រោះជនជាតិយូដា*

៦. តើអ្នកគិតថាព្រះមានផែនការអ្វីសម្រាប់អ្នក? *ទុកឲ្យកុមារជាអ្នកឆ្លើយ*

**៧. ល្បែងកំសាន្ត «ជញ្ជូនក្រូចឆ្មាបន្តគ្នា»**




**សម្ភារៈដែលត្រូវការ៖** ស្លាបព្រា ក្រូចឆ្មារ៣០ និងកញ្ជែង៦

១.ចែកកុមារជាបីក្រុម ហើយដាក់កញ្ជែង នៅពីមុខ១ និងពីក្រោយ១

២.ដាក់ក្រូចឆ្មារ១០នៅក្នុងកញ្ជែងខាងមុខហើយឲ្យស្លាបព្រាទៅកុមារគ្រប់គ្នា

៣. ឲ្យកុមារទីមួយដែលឈរជាជួរនោះ ព្យាយាមយកក្រូចឆ្មារពីកញ្ជែងដោយប្រើបានតែស្លាបព្រាតែប៉ុណ្ណោះ (មិនអាចប្រើដៃបានទេ) ហើយបន្ទាប់មកបញ្ជូនក្រូចឆ្មារនោះទៅកុមារបន្ទាប់។ បន្តបញ្ជូនក្រូចនោះ រហូតទៅដល់កុមារចុងក្រោយ។ ប្រសិនក្រូចនោះធ្លាប់នោះគេមិនអាចរើសវាបាននោះទេ។

៤. ក្រុមណាដែលអាចជញ្ជូនក្រូចឆ្មារបានច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះបានប្រើអេសធើរ ដើម្បីការពារដល់ជនជាតិយូដា។ ក៏ដូចគ្នានេះដែរ សម្រាប់ល្បែងនេះអ្នកបានការពារដល់ក្រូចឆ្មារមិនឲ្យធ្លាក់។ នៅក្នុងជីវិតរស់នៅព្រះបានមានផែនការដ៏អស្ចារ្យសម្រាប់យើងរាល់គ្នា។ ហើយព្រះអង្គនឹងជួយអ្នកឲ្យបំពេញការនោះ ដូចជាទ្រង់បានជួយដល់អេសធើរអីចឹងដែរ។

**៨. ខគម្ពីរចងចាំ អេភេសូ ២:១០**

**៩. ហត្ថកម្ម «អេសធើរសង្គ្រោះជាតិសាសន៍របស់នាង»**

**សម្ភារៈដែលត្រូវការ៖** ព្រីនក្រដាសហត្ថកម្ម កូល័រ កន្ត្រៃ និងការបិត

១. ព្រីនក្រដាសហត្ថកម្មរូបម្កុដ ឲ្យកុមារម្នាក់មួយសន្លឹកហើយឲ្យពួកគេតុបតែងវា។

២. កាត់រូបម្កុដ និងរូបបន្ទាត់ពីរនោះចេញមក រួចបិតភ្ជាប់វាជាមួយគ្នាដើម្បីធ្វើជាម្កុដមួយ។

៣. សូមពន្យល់កុមារថា បើទោះបីជាយើងគ្រាន់តែជាមនុស្សធម្មតាក៏ដោយ ព្រះចង់ឲ្យយើងធ្វើនូវរឿងអស្ចារ្យនៅថ្ងៃអនាគត! សូមឲ្យយើងបានចងចាំពីការសន្យារបស់ព្រះអង្គ និងស្តាប់បង្គាប់ទ្រង់ជានិច្ច។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*


បិតទីនេះ:
បិតទីនេះ: